ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុប្បយោគផ្ទៃដីទំហំ ១៩៧ (មួយរយកៅសិបប្រាំពីរ) ហិកតា ស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិសមុទ្រព្រះសីហនុរាម ខេត្តព្រះសីហនុ ផ្តល់ជូនក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៨៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការធ្វើអនុប្បយោគផ្ទៃដីទំហំ ១៤០៨ហិកតា ស្ថិតក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ«រាម» ស្រុកព្រៃនប់ខេត្តព្រះសីហនុ
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកែប្រែតំបន់ការពារធម្មជាតិពីឧទ្យានជាតិព្រះសីហនុ«រាម» ទៅជាឧទ្យានជាតិសមុទ្រព្រះសីហនុរាម
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ស្តីពីការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិសមុទ្រព្រះសីហនុរាម

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

**សម្រេច**

**មាត្រា១.-**

ត្រូវបានធ្វើអនុប្បយោគផ្ទៃដីទំហំ ១៨៧ (មួយរយប៉ែតសិបប្រាំពីរ) ហិកតា ស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃឧទ្យានជាតិសមុទ្រព្រះសីហនុរាម លើផ្ទៃដីវិនិយោគមួយផ្នែកនៃគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន Lixin Development Co.,Ltd និងក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ក្នុងភូមិសាស្ត្រឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ សម្រាប់ផ្តល់ជូនក្រសួងការពារជាតិ ដើម្បីប្រើប្រាស់ក្នុងវិស័យការពារជាតិ ដែលក្នុងនោះផ្ទៃដីទំហំ ១៥៧ (មួយរយហាសិបប្រាំពីរ) ហិកតា សម្រាប់បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការដ្ឋាន និងផ្ទៃដីទំហំ ៣០ (សាមសិប) ហិកតា សម្រាប់រក្សាជាទីតាំងដាក់ប្រព័ន្ធរ៉ាដានៃកងទ័ពជើងទឹក ដូចមានភ្ជាប់ក្នុងផែនទី និងចំណុចនិយាមកាក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃព្រហស្បតិ៍ ៥ រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងចំណុចនិយាមការបស់ដីនៃលិខិតលេខ ១៩៣ អនក្រ.បក ថ្ងៃព្រហស្បតិ៍ ៥ កើត ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២២




| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 349429.398 | 1164337.025 | 34 | 350683.793 | 1166998.938 | 67 | 350364.918 | 1165140.921 |
| 2 | 349445.652 | 1164373.634 | 35 | 350766.904 | 1167156.335 | 68 | 350311.918 | 1165066.920 |
| 3 | 349473.411 | 1164410.966 | 36 | 350789.005 | 1167223.346 | 69 | 350184.918 | 1164923.920 |
| 4 | 349535.000 | 1164462.210 | 37 | 350817.850 | 1167269.603 | 70 | 350195.918 | 1164793.920 |
| 5 | 349594.504 | 1164504.374 | 38 | 350866.312 | 1167298.364 | 71 | 349856.917 | 1164518.920 |
| 6 | 349702.644 | 1164656.981 | 39 | 350890.265 | 1167304.000 | 72 | 349780.917 | 1164523.920 |
| 7 | 349755.015 | 1164698.124 | 40 | 350951.265 | 1167354.000 | 73 | 349730.917 | 1164485.920 |
| 8 | 349971.717 | 1164830.990 | 41 | 351054.265 | 1167241.000 | 74 | 349734.524 | 1164429.952 |
| 9 | 350020.833 | 1165008.345 | 42 | 350980.265 | 1167106.000 | 75 | 349595.265 | 1164389.000 |
| 10 | 350018.045 | 1165054.263 | 43 | 350967.265 | 1167055.000 | 76 | 349598.000 | 1164189.000 |
| 11 | 350016.595 | 1165122.900 | 44 | 350983.265 | 1166979.000 | 77 | 349634.000 | 1164150.000 |
| 12 | 350033.539 | 1165224.080 | 45 | 351028.265 | 1166815.000 | 78 | 349666.000 | 1164088.000 |
| 13 | 350076.566 | 1165291.622 | 46 | 351044.265 | 1166727.000 | 79 | 349656.000 | 1164050.000 |
| 14 | 350198.598 | 1165378.854 | 47 | 351110.265 | 1166645.000 | 80 | 349600.000 | 1164016.000 |
| 15 | 350216.718 | 1165400.095 | 48 | 351152.265 | 1166584.000 | 81 | 349538.000 | 1164013.000 |
| 16 | 350232.065 | 1165446.588 | 49 | 351147.265 | 1166468.000 | 82 | 349478.000 | 1164004.000 |
| 17 | 350254.551 | 1165499.491 | 50 | 351073.265 | 1166404.000 | 83 | 349376.000 | 1163986.000 |
| 18 | 350312.030 | 1165551.951 | 51 | 351065.265 | 1166383.000 | 84 | 349255.000 | 1163968.000 |
| 19 | 350428.780 | 1165943.524 | 52 | 351060.265 | 1166264.000 | 85 | 349244.000 | 1163702.000 |
| 20 | 350435.227 | 1165978.813 | 53 | 351002.265 | 1166187.000 | 86 | 349380.000 | 1163494.000 |
| 21 | 350435.227 | 1166061.978 | 54 | 350988.265 | 1166140.000 | 87 | 349297.000 | 1163432.000 |
| 22 | 350419.716 | 1166105.812 | 55 | 350994.265 | 1166111.000 | 88 | 349159.000 | 1163387.000 |
| 23 | 350394.206 | 1166163.789 | 56 | 351025.265 | 1165992.000 | 89 | 349080.000 | 1163371.000 |
| 24 | 350450.604 | 1166413.306 | 57 | 351002.265 | 1165933.000 | 90 | 348917.000 | 1163347.000 |
| 25 | 350451.541 | 1166444.375 | 58 | 350843.265 | 1165767.000 | 91 | 348856.000 | 1163355.000 |
| 26 | 350443.007 | 1166457.733 | 59 | 350790.265 | 1165748.000 | 92 | 348781.000 | 1163348.000 |
| 27 | 350445.767 | 1166545.670 | 60 | 350591.265 | 1165743.000 | 93 | 348694.000 | 1163340.000 |
| 28 | 350478.025 | 1166615.760 | 61 | 350554.265 | 1165722.000 | 94 | 348569.000 | 1163332.000 |
| 29 | 350528.030 | 1166658.810 | 62 | 350610.265 | 1165624.000 | 95 | 348528.000 | 1163321.000 |
| 30 | 350604.137 | 1166747.418 | 63 | 350621.265 | 1165473.000 | 96 | 348531.000 | 1163722.000 |
| 31 | 350640.909 | 1166870.775 | 64 | 350607.919 | 1165275.921 | 97 | 348536.000 | 1163781.000 |
| 32 | 350653.583 | 1166913.021 | 65 | 350504.919 | 1165246.921 | 98 | 348650.000 | 1163949.000 |
| 33 | 350656.955 | 1166942.616 | 66 | 350446.919 | 1165219.921 | 99 | 348814.000 | 1164144.000 |

**សញ្ញាសំគាល់**

- ● ចំណុចនិយាមកាព្រំប្រទល់
- ── ខ្សែរយៈកំពស់
- ▭ ទីតាំងដីទំហំ១៨៧ហិកតា

0 650 1,300 Meters

Map Information:
Units: meters
System: UTM, Zone 48 N
Datum: WGS 1984

